ទីស្តីការក្រសួងយុត្តិធម៌
លេខ ០១.៣.១.សរ-៩៧

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

លោក ប្រធានតុលាការកំពូល និងលោកអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
លោក ប្រធានសាលាឧទ្ធរណ៍ នងលោកព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
លោក ប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង
លោក ប្រធានតុលាការយោធា និងលោកព្រះរាជអជ្ញាអមតុលាការយោធា

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ។
**យោង:** មាតិកា ៤ ស្តីពីបទល្មើសឧក្រិដ្ឋ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០-០៩-៩២ ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា ការផ្តន្ទាទោសជនល្មើសដែលជាប់ចោទពីបទឧក្រិដ្ឋនៅមានកម្រិតទាបស្រាល ដែលជាហេតុធ្វើអោយអំពើល្មើសបែបនេះគ្មានការថយចុះសោះ ។

ក្រសួងសូមអោយលោកយកចិត្តទុកដាក់ចាប់អារម្មណ៍ក្នុងការបង្ក្រាបបទល្មើសនេះ ឱ្យបានទទួលលទ្ធផលជាអតិបរមាដោយពិនិត្យពិចារណាអោយបានល្អិតល្អន់និងហ្មត់ចត់ជាទីបំផុតចំពោះស្ថានសម្រាល និងស្ថានទម្ងន់ទោស ទៅលើអំពើរបស់ឧក្រិដ្ឋជនទាំងនោះអោយបានច្បាស់លាស់ និងប្រាកដប្រជាទៅតាមសកម្មភាពរបស់ឧក្រិដ្ឋជនដែលបានប្រព្រឹត្តដើម្បីកំណត់បទល្មើស និងទោសទណ្ឌកម្មអោយបានត្រឹមត្រូវទៅតាមមាត្រា ៣១ ដល់មាត្រា ៣៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សូមលោកចាប់អារម្មណ៍អោយបានខ្ពស់ថា អង្គការតុលាការនិងអង្គការអយ្យការ ជាអង្គការបង្ក្រាបបទល្មើសដោយផ្អែកលើច្បាប់ ។ ដូច្នេះអំណើះតទៅចំពោះជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋ គប្បីអស់លោកអនុវត្តឱ្យបានតឹងរឹងនិងហ្មត់ចត់ជាទីបំផុតផ្អែកតាមច្បាប់ជាធរមាន ។

ក្រសួងសង្ឃឹមថា អស់លោកប្រធានតុលាការ និងព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ទាំងអស់នឹងយកចិត្តទុកដាក់អនុវត្តតាមការណែនាំនេះអោយល្អប្រសើរ ដើម្បីបន្ថយអំពើល្មើសឧក្រិដ្ឋឱ្យបានថយចុះក្នុងគោលដៅជំរុញប្រទេសជាតិយើងអោយឈានទៅកាន់នីតិរដ្ឋ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្នួន**